ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

# សារថ្វាយព្រះពរ

## ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស
## ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៦៤ យាងចូល ៦៥ ព្រះវស្សា

**បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

ក្នុងឱកាសដ៏សែននក្ខត្តឫក្សមហាប្រសើរថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៦៤ យាងចូល ៦៥ ព្រះវស្សារបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ ទូលព្រះបង្គំខ្ញុំ តាងនាមឱ្យសមាជិក សមាជិកា ក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីរាជការទាំងអស់ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានមហាកិត្តិយសប្រកបដោយបីតិសោមនស្សរីករាយជាអនេក សូមព្រះបរមរាជានុញ្ញាតថ្វាយព្រះពរជ័យមង្គលបវរសួស្តីមហាប្រសើរ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង មានព្រះកាយពលមាំមួន ព្រះសុខភាពបរិបូណ៌ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ប្រថាប់ក្នុងព្រះបរមសិរីរាជសម្បត្តិ ទ្រង់គង់ជានិមិត្តរូបនៃឯកភាពជាតិ និរន្តរភាពជាតិ និងទ្រង់ធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានស្ថិតស្ថេរចីរកាល ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវកតញ្ញូតាធម៌ថ្វាយចំពោះព្រះករុណាជាអម្ចាស់ ដោយស្វាមីភក្តិជាទីបំផុត និងប្តេជ្ញាដង្ហែតាមព្រះរាជកិច្ចគ្រងរាជសម្បត្តិដ៏ភ្លឺស្វាង ប្រកបដោយព្រះគតិបណ្ឌិត និងព្រះទសពិធរាជធម៌របស់ព្រះអង្គដែលញ៉ាំងឱ្យព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ។

ជាថ្មីម្តងទៀតទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកមានទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបរមវិញ្ញាណក្ខន្ធនៃព្រះអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមប្រទានពរជ័យបវរសួស្តីជ័យមង្គលដល់ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា សូមទ្រង់បានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ៚

សូមក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០១៧

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**អ៊ឹម ឈុនលឹម**